ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៦ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០៩-៧-១៩៩៦	អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការបង្កើតអាជ្ញាធរ អភិវឌ្ឍន៍ កំពង់ផ្លាំង ទទួលបន្ទុកការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង	១១៣៦
១១-៧-១៩៩៦	អនុក្រឹត្យលេខ ១២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១១៣៨
១២-៧-១៩៩៦	អនុក្រឹត្យលេខ ១២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១១៤០
១២-៧-១៩៩៦	អនុក្រឹត្យលេខ ១២៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	១១៤២
១២-៧-១៩៩៦	អនុក្រឹត្យលេខ ១២៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១១៤៣
១២-៧-១៩៩៦	អនុក្រឹត្យលេខ ១២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១១៤៤
១៥-៧-១៩៩៦	អនុក្រឹត្យលេខ ១៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១១៤៥

២ - សេចក្តីសំរេច

១២-៧-១៩៩៦	សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការផ្ទេរសិទ្ធិ	១១៤៦

II - ការងារបណ្តាក្រសួង

១ - អន្តរក្រសួង មហាផ្ទៃ - ការពារជាតិ

១១-៧-១៩៩៦	ប្រកាសអន្តរក្រសួងលេខ ២៧៨ ប្រ.ក ស្តីពីល័ក្ខខ័ណ្ឌនៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ	១១៤៧

២ - អន្តរក្រសួង សាធារណការ និង ដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - មហាផ្ទៃ

១០-៧-១៩៩៦	ប្រកាសរួមលេខ ២៨១ ប្រក.សក ស្តីពីការបន្តផ្តល់ផ្លាកលេខរថយន្តចង្កូតស្តាំ	១១៥៤

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១០-៧-១៩៩៦	ប្រកាសលេខ ៤៥៩ ប្រក. ផក អនុញ្ញាតអោយក្រុមហ៊ុនសាន់ឌី ក្ខូអែលធីឌី(SANDY CO.LTD) តំណាងដោយលោក ជា សាន ជនជាតិខ្មែរ បង្កើតរោងចក្រផ្លាស្ទិក	១១៥៦
១៥-៧-១៩៩៦	ប្រកាសលេខ ៤៦៣ ផក. ប្រក អនុញ្ញាតអោយលោក ហេង ហ៊ុយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ម្ចាស់សិប្បកម្មស្រាកែច្នៃ បើកសាខាផលិតកម្មស្រាកែច្នៃ ចំនួន ១ កន្លែង	១១៥៧

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួង ពត៌មាន

ប្រកាស

១២-៧-១៩៩៦	ប្រកាសលេខ ២២៦/៩៦ ពម. មពប្រក អនុញ្ញាតអោយសារពត៌មានឈ្មោះសាធារណរដ្ឋ ដំណើរការបោះពុម្ពឡើងវិញ	១១៥៨
១២-៧-១៩៩៦	ប្រកាសលេខ ២២៧/៩៦ ពម. មពប្រក អនុញ្ញាតជូនអ្នកស្រី លី ហួរ បើកអាជីវកម្មបោះពុម្ពផ្លាកសញ្ញាផលិតលើកេសក្រដាស « ភ្នំពេជ្រ »	១១៦០

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១ - ប្រកាស

១១-៧-១៩៩៦	ប្រកាសលេខ ៣៨២ ប្រក. កសក. ចត ស្តីពីការតែងតាំងមន្ត្រីរាជការ	១១៦១

២ - សេចក្តីសំរេច

១៥-៧-១៩៩៦	សេចក្តីសំរេចលេខ ៣៨៥ សសរ. កសក. ចត ស្តីពីការតែងតាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សាសំរាប់ឆ្នាំសិក្សា ១៩៩៦	១១៦២

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

១១-៧-១៩៩៦ ប្រកាសលេខ ១២២ ប្រក.វវសបុ ស្តីពីការបង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ និងកំណែស្នាដៃបច្ចេកទេសសំរាប់ការប្រឡងបញ្ចប់បរិញ្ញា ឆ្នាំសិក្សា ១៩៩៥- ៩៦ របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ១១៦៥

៧ - ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

១៤-៧-១៩៩៦ ប្រកាសលេខ ៦៥១ អយក.ប្រក អនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់គ្រូ « គណិតវិទ្យា ថ្នាក់ទី ៧ » ១១៦៨

៨ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

០៩-៧-១៩៩៦ ប្រកាសលេខ ១២៦៥ ប្រក.អជប ស្តីពីការចាត់តាំងមន្ត្រីរាជការអោយធ្វើជាដៃគូរជាមួយជំនាញការក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទកម្ពុជា ឥណ្ឌូនេស៊ី (Indonesia cambodia Rural Development Project) ១១៧០

៩ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងបរិស្ថាន

ប្រកាស

០៩-៧-១៩៩៦ ប្រកាសលេខ ១១៦៤ បស្ថ ស្តីពីការតែងតាំង និងតម្លើងឋានៈមន្ត្រីរាជការ ១១៧១

០៩-៧-១៩៩៦ ប្រកាសលេខ ១១៦៥ បស្ថ ស្តីពីការតែងតាំង និងតម្លើងឋានៈមន្ត្រីរាជការ ១១៧២

០៩–៧–១៩៩៦ ប្រកាសលេខ ១១៦៦ បស្ក ស្ដីពីការតែងតាំង និងតម្លើងឋានៈមន្ត្រីរាជការ ១១៧៣

១០ - រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្ដីសំរេច

១២–៧–១៩៩៦ សេចក្ដីសំរេចលេខ ៤៣៨ សសរ.មស.ក្រខ ស្ដីពីការបែងចែកសិស្សនិស្សិត ចំនួន ១០ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស ១១៧៤

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ៣៤ អនក្រ.បក

ស្តីពីការបង្កើតអាជ្ញាធរអភិវឌ្ឍន៍កំពង់ឆ្នាំងទទួលបន្ទុក

ការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតអាជ្ញាធរអភិវឌ្ឍន៍កំពង់ឆ្នាំង ទទួលបន្ទុកការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង ដោយក្រុមហ៊ុនចំរុះ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន DRAGON GOLD SDN BHD ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** និង ឯកឧត្តម **ម៉ែន សំអុន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬ តំណាង ជាសហប្រធាន

២-ឯកឧត្តម **ណូ ឌីតាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល ឬ តំណាង ជាលេខាធិការ

៣-ឯកឧត្តម **ប៉ុក សំងល** រដ្ឋលេខាធិការអាកាសចរស៊ីវិល ឬតំណាង ជាសមាជិក

៤-ឯកឧត្តម **គ្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង ជាសមាជិក

៥-ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិឬតំណាង ជាសមាជិក

៦-ឯកឧត្តម **ហេង វង្សប៊ុនឆាត** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ឬតំណាង ជាសមាជិក

៧-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ជាសមាជិក

៨-ឯកឧត្តម **ម៉ម សុផាណា** អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន ឬតំណាង ជាសមាជិក

៩-អ្នកអង្គម្ចាស់ **នរោត្តម ម៉ារ៉ាត់ ម៉ារ៉ានី** មេបញ្ជាការទ័ពអាកាសខ្មែរ ឬតំណាង ជាសមាជិក

១០-តំណាងនៃក្រុមប្រឹក្សានគរោបនីយកម្ម ជាសមាជិក

១១-ឯកឧត្តម **គោក សាម៉ឿន** អភិបាលខេត្តកំពង់ឆ្នាំង និង ឯកឧត្តម **ឡាច សួគ** អភិបាលរងទី ១ ឬតំណាង ជាសមាជិក

១២-បណ្ឌិត **ចុង គួង យូអាន** (Dr. Chong Kwong Yuan) និង បណ្ឌិត **យាន ហ្គ្រេយ** (Dr. Iain Gray) តំណាងរបស់ក្រុម ?ិន

DRAGONGOLD SDN BHD ឬតំណាង ជាសមាជិក

មាត្រា ២ : អាជ្ញាធរនេះ មានភារកិច្ចទទួលបន្ទុកពិនិត្យសិក្សាលើកិច្ចព្រមព្រៀង និងគ្រប់គំរោង សំរាប់ការអភិវឌ្ឍន៍ព្រលានយន្តហោះកំពង់ឆ្នាំង របស់ក្រុមហ៊ុនវិនិយោគ DRAGONGOLD SDN BHD ដើម្បីជ្រើសរើស និងស្នើជាយោបល់ថ្វាយ និង ជូននាយករដ្ឋមន្ត្រីសំរេច ។ ក្រោយពីមានការសំរេចជាគោលការណ៍ អាជ្ញាធរមានភារកិច្ចរៀបចំពិនិត្យលំអិត និងចុះហត្ថលេខាលើកិច្ចសន្យាជា មួយក្រុមហ៊ុនក្នុងនាមរាជរដ្ឋាភិបាល ។

មាត្រា ៣ : អាជ្ញាធរនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយដើម្បីជួយការងារ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សម្តេច ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងមាត្រា១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១២៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជនដែលមាន សទ្ធាជ្រះថ្លាបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមកសាងវត្តវិហារសំណរ ក្នុងស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមតាមលំដាប់ថ្នាក់ខាងក្រោម ÷

ក–មេដាយមាស :

១–លោក ង៉ែ **ហុកឈួន** និង អ្នកស្រី **អ៊ុំ ស៊ីស្រ៊ន** បរិច្ចាគប្រាក់ចំនួន ១៤៨.៦១៥ ដុល្លារអាមេរិក

២–លោក **តាំង ម៊ុន** និង អ្នកស្រី បរិច្ចាគប្រាក់ ១០.០០០ ដុល្លារអាមេរិក

៣–លោក **ឈិន តីឈី** បរិច្ចាគប្រាក់ ១០.០០០ ដុល្លារអាមេរិក

ខ–មេដាយសំរិទ្ធ :

១–លោក **ម៉ា សុជាតិវង្ស** បរិច្ចាគប្រាក់ ៣.០០០ ដុល្លារអាមេរិក

២–លោក **ហុក ខាន់** បរិច្ចាគប្រាក់ ៣.០០០ ដុល្លារអាមេរិក

៣–លោក **ហុក ស៊ុំ** បរិច្ចាគប្រាក់ ៣.០០០ ដុល្លារអាមេរិក

៤–លោក **អៀ ម៉ុនភាព** បរិច្ចាគប្រាក់ ៣.០០០ ដុល្លារអាមេរិក

៥–លោក **ឡុង សេង** បរិច្ចាគប្រាក់ ៣.០០០ ដុល្លារអាមេរិក

៦–លោកស្រី	**អ៊ុង ឆេង**	បរិច្ចាគប្រាក់	៣.០០០	ដុល្លារអាមេរិក
៧–លោក	**គន់ ជា**	បរិច្ចាគប្រាក់	៣.០០០	ដុល្លារអាមេរិក
៨–លោកតា	**ហ៊ុន នាង**	បរិច្ចាគប្រាក់	៣.០០០	ដុល្លារអាមេរិក
៩–លោក	**តាំង ហុងឆាយ**	បរិច្ចាគប្រាក់	៣.០០០	ដុល្លារអាមេរិក
១០–លោក	**អ៊ុង ស៊ីធួន**	បរិច្ចាគប្រាក់	៣.០០០	ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាលត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១២៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ

ព្រះរាជាណាចក្រកម្ពុជា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគថវិកាជួយកសាងសង់អាគារសិក្សានៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ÷

ក—មេដាយមាស :

១–លោក JAI SANKAR SAMAR ប្រធានអង្គការទស្សនៈពិភពលោក ជួយកសាងអាគារមួយខ្នង អស់ទឹកប្រាក់ ២០.៥០០ $US

២–លោក TRI BUDIARDJO អនុប្រធានអង្គការទស្សនៈពិភពលោក ជួយសាងសង់អគារមួយ ខ្នង អស់ទឹកប្រាក់ ១៨.០០០ $US

៣–លោក **តូរ៉ូ វ៉ាតាណាបេ** និង លោកស្រី **ជីអេកូ វ៉ាតាណាបេ** ជួយសាងសង់អាគារមួយខ្នងអស់ទឹកប្រាក់ ១៣.៣៩២ $US

ខ—មេដាយសំរិទ្ធ :

១–លោកស្រី **គា ឡាលី** តំណាងអង្គការទស្សនៈពិភពលោក ប្រចាំការស្រុកអង្គស្នួលជួយសាងសង់មត្តេយ្យសាលាមួយបន្ទប់ និង ផ្ទះបាយមួយ អស់ទឹកប្រាក់ ៣.១០០ $ US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១២៧ អនក្រ.តត

ស្ដីពីការជូនមេដាយសហមេត្រី

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយសនៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ អស្សឫទ្ធិ សហមេត្រីជូនចំពោះលោកវរសេនីយ៍ឯក Henri FRANCQ ប្រធានក្រុមបេសកកម្មយោធានៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា និង ជាទីប្រឹក្សាមេបញ្ជាការកងរាជអាវុធហត្ថជាតិ ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយចំណងមិត្តភាព និង សហប្រតិបត្តិការ យោធាបារាំង – ខ្មែរ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួង ការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ដលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១២៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ ។

សំរេច

មាត្រា ១ : តែងតាំងលោកស្រី **យស់ ម៉ារាណា** អនុប្រធាននាយកដ្ឋានពិធីការ ជាទីប្រឹក្សានិងភារៈធារីនៅស្ថានទូតសាធារណរដ្ឋឆែកជំនួសលោក **លឹម សំកុល** ដែលត្រូវផ្លាស់អោយមកបំរើការងារនៅក្នុងប្រទេសវិញដោយចប់អាណត្តិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង លោកស្រី **យស់ ម៉ារាណា** ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះ

ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១២៩ អនក្រ.តត

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

សំរេច

មាត្រា ១ : តែងតាំងលោក **និន សុខលាន** នាយករងខុទ្ទកាល័យរដ្ឋមន្ត្រី ជាទីប្រឹក្សា និងភារៈធារីនៅស្ថានទូតសាធារណរដ្ឋប៊ុលហ្គារី ជំនួសលោក **គង់ សារ៉ាត** ដែលត្រូវផ្លាស់អោយមកបំរើការងារនៅក្នុងប្រទេសវិញដោយចប់អាណត្តិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងលោក **និន សុខលាន** ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៣០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

សំរេច

មាត្រា ១ : តែងតាំងលោក **ឡុង ផុន** ប្រធាននាយកដ្ឋានកុងស៊ុល-ច្បាប់ ជាអគ្គទីប្រឹក្សា និងភារៈធារីនៅស្ថានទូតសាធារណរដ្ឋហុងគ្រី ជំនួសលោក **ជាំ សូផុន**

ដែលត្រូវផ្លាស់អោយមកបំរើការងារនៅក្នុងប្រទេសវិញដោយចប់អាណត្តិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ និងលោក **ឡុង ផុល** ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ : ២៨ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

សំរេច

មាត្រា ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **តុល ឡោះ** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ជារដ្ឋមន្ត្រីស្តីទីនៃ ក្រសួងធម្មការ និង សាសនាជំនួយឯកឧត្តម **ឆៀង វណ្ណារិទ្ធ** ត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេសចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **តុល ឡោះ** ត្រូវទទួលបន្ទុកសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II - ការិយាល័យក្រសួង

ប្រកាសអន្តរក្រសួង

១ - អន្តរក្រសួងមហាផ្ទៃ - ការពារជាតិ

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ២៧៨ ប្រ.ក

ស្តីពីល័ក្ខខ័ណ្ឌ នៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់

អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៣ ស្តីពីការ បង្កើតក្រសួងការពារ ជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញការចាំបាច់របស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ

សំរេច

ប្រការ ១ : ជនណាមានសិទ្ធិប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គល ដូចមានចែងក្នុងមាត្រា ៨ មាត្រា ៩ និង មាត្រា ១០ នៃអនុក្រឹត្យលេខ ៦២ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ ទើបមានសិទ្ធិធ្វើពាក្យសុំលិខិតអនុញ្ញាតប្រើប្រាស់អាវុធ មកស្ថាប័នមានសមត្ថកិច្ច និង បំពេញល័ក្ខខ័ណ្ឌតាមការកំណត់ដូចខាងក្រោមនេះ ៖

I–កងកំលាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និង ជនស៊ីវិល

ក–ចំពោះកងកំលាំងនគរបាលជាតិ :

–កងកំលាំងនគរបាលជាតិតាមអង្គភាពចំណុះទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ត្រូវធ្វើពាក្យស្នើសុំដោយមានការបញ្ជាក់ និងចុះហត្ថលេខាទទួលស្គាល់តាមឋានានុក្រម ដើម្បីនាយកដ្ឋាននគរបាលដាក់ជូនអគ្គនាយកនគរបាលជាតិពិនិត្យ និង សំរេច ។

–កងកំលាំងនគរបាលជាតិ ចំណុះស្នងការដ្ឋាននគរបាលខេត្ត–ក្រុង ឬ អធិការដ្ឋាននគរបាលស្រុក ខ័ណ្ឌ ត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ពីប្រធានការិយាល័យ ឬ អធិការនគរបាលស្រុក ខ័ណ្ឌ ដើម្បីការិយាល័យជំនាញដាក់ជូនស្នងការពិនិត្យ និង សំរេច ។

ខ–ចំពោះមន្ត្រីរាជការស៊ីវិល :

–មន្ត្រីរាជការស៊ីវិលតាមក្រសួង ស្ថាប័នត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ ចាប់ពីថ្នាក់នាយកខុទ្ទកាល័យឡើងទៅ ដើម្បីនាយកដ្ឋាននគរបាល រដ្ឋបាល ដាក់ជូនអគ្គ នាយកនគរបាលជាតិពិនិត្យ និង សំរេច ។

–មន្ត្រីរាជការស៊ីវិលតាមខេត្ត–ក្រុង ត្រូវធ្វើពាក្យស្នើសុំដោយបញ្ជាក់ និង ចុះហត្ថលេខាទទួលស្គាល់ពីខុទ្ទកាល័យខេត្ត–ក្រុង ឬ ពីប្រធានមន្ទីរជុំវិញខេត្ត–ក្រុង ដើម្បីការិយាល័យជំនាញដាក់ជូន ស្នងការពិនិត្យ និង សំរេច ។

គ–ចំពោះជនស៊ីវិល លក្ខខ័ណ្ឌនៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់ អាវុធ និង ជាតិផ្ទុះ គ្រប់ប្រភេទនឹងត្រូវមានការកំណត់ដោយឡែក យោលទៅតាម សំណូមពរចាំបាច់ និង មានការសំរេចពី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ឃ–អ្នកសុំត្រូវបំពេញតាមតារាងរៀបរាប់ អាវុធមានបិទតែមប្រិយ៍តាមការកំណត់របស់ច្បាប់ និង រូបថត ទំហំ ៣×៤ ចំនួន ០៤ សន្លឹក (ថតចំពីមុខមិនពាក់វ៉ែនតា ចំពោះកងកំលាំងនគរបាលជាតិ រូបថតត្រូវស្លៀកពាក់ឯកសណ្ឋានមិនពាក់មួក) ។

ង–ពេលដែលបំពេញបែបបទលើតារាងរៀបរាប់រួចហើយ នាយកដ្ឋាននគរបាលរដ្ឋបាលត្រូវ ចេញបង្កាន់ដៃទទួលស្គាល់អាវុធបណ្តោះអាសន្នអោយសាមីជន ។ អាវុធត្រូវយកមកពិនិត្យលក្ខណៈបច្ចេកទេស នៅនាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ បើនៅក្រសួង ឬ ការិយាល័យបច្ចេកទេស បើនៅខេត្ត–ក្រុង ។

ច–គំរូលិខិតអនុញ្ញាតប្រើប្រាស់អាវុធមាន ០៤ ប្រភេទមានទំហំ ១០,៣០ សម × ៧,៥០ សម ដូចគ្នា ។

–ប្រភេទទី ១ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធយកតាមខ្លួនរបស់នគរបាលជាតិមានពណ៌ (ស) មានរូបទង់ជាតិបញ្ឆិតលើផ្ទៃខាងក្រៅ និង មានសញ្ញា (រូបសឹង្ហចំកណ្តាល) ។

–ប្រភេទទី ២ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធអង្គភាពរបស់កងកំលាំងនគរបាលជាតិ មានពណ៌ (លឿង) ។ មានរូបទង់ជាតិបញ្ឆិតពីលើផ្ទៃខាងក្រៅ និង មានសញ្ញា (រូបសឹង្ហចំកណ្តាល) ។

–ប្រភេទទី ៣ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធយកតាមខ្លួនរបស់ស្ថាប័នស៊ីវិលមានពណ៌ (ស) មានសញ្ញារូបទង់ជាតិបញ្ឆិតលើផ្ទៃខាងក្រៅ ។

–ប្រភេទទី ៤ : លិខិតអនុញ្ញាតប្រើប្រាស់អាវុធអង្គភាពរបស់ស្ថាប័នស៊ីវិលមានពណ៌ (ខៀវ) មានរូបទង់ជាតិបញ្ឆិតលើផ្ទៃខាងក្រៅ ។

II–ចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល :

កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល ដែលមានសិទ្ធិប្រើប្រាស់អាវុធ ជាលក្ខណៈបុគ្គល ត្រូវបានកំណត់ដូចខាងក្រោម ÷

ចំពោះទ័ពប្រយុទ្ធ :

–យោធិនមានសិទ្ធិប្រើប្រាស់អាវុធខ្លីបាន គឺត្រូវមានឋានន្តរសក្តិចាប់ពីនាយចំណង់ឡើងទៅ ។

ចំពោះទ័ពបំរើការប្រយុទ្ធ :

–យោធិនមានសិទ្ធិប្រើប្រាស់អាវុធខ្លីបាន គឺត្រូវមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ទោឡើង ទៅ ។

ដោយឡែកយោធិនដែលពុំទាន់មានឋានន្តរសក្តិដូចការកំណត់ខាងលើ តែអាចមានសិទ្ធិប្រើប្រាស់អាវុធខ្លីបានក្នុងករណីមានភារកិច្ចចាំបាច់ និង ត្រូវបានការអនុញ្ញាតអោយប្រើប្រាស់ជាកងឯកភាព គឺអាចអាទិភាពបានដូចជាជំនាញស្រាវជ្រាវ

ការិយាល័យទី ២ អាកាសយានិក ហិរញ្ញវត្ថុ អយ្យការ តុលាការ កងការពារថ្នាក់ដឹកនាំ ភ្នាក់ងារសារទូរលេខ និងភ្នាក់ងារផ្សេងៗ ។ ក្រៅពីការបំពេញបេសកកម្ម មិនអនុញ្ញាតអោយយកអាវុធខ្លីតាមខ្លួន ហើយត្រូវរក្សាទុកនៅផ្ទះ ឬ នៅតាមកងឯកភាពខ្លួន ។

ក្រសួងការពារជាតិ ប្រគល់សិទ្ធិការចេញប័ណ្ណប្រើប្រាស់អាវុធខ្លី ជាសមត្ថកិច្ចរបស់អគ្គសេនាធិការជាអ្នកចេញប័ណ្ណ ។ គ្រប់កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ត្រូវធ្វើពាក្យស្នើសុំប័ណ្ណផ្តល់អោយគ្រប់យោធិនទាំងឡាយណាដែលមានអាវុធខ្លី និងមានសិទ្ធិប្រើប្រាស់ ហើយបានបញ្ចូលចំនួនអាវុធនោះក្នុងបញ្ជីគ្រប់គ្រងរបស់កងឯកភាព ។ ពាក្យស្នើសុំត្រូវបញ្ជាក់ទទួលស្គាល់របស់មេបញ្ជាការកងឯកភាពហើយផ្ញើជូនមកការិយាល័យទី ៤ (ផ្នែកអាវុធ) រៀបចំសំណុំបែបបទជូនអគ្គសេនាធិការពិនិត្យសំរេច ដោយឆ្លងតាមរយៈការិយាល័យទី ១ អគ្គសេនាធិការពិនិត្យ និង បញ្ជាក់ទទួលស្គាល់ យោធិនទាំងនោះ ។

យោធិនទាំងអស់មិនអនុញ្ញាតអោយប្រើប្រាស់អាវុធវែង ជាលក្ខណៈបុគ្គលឡើយ លើកលែងតែកងការពារថ្នាក់ដឹកនាំ និង បញ្ហាបេសកកម្ម ពេលចប់ភារកិច្ចត្រូវយកអាវុធទុកក្នុងកងឯកភាព មិន អនុញ្ញាតអោយយកអាវុធទុកតាមខ្លួនឡើយ ។

ប្រការ ២ : អំពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រើប្រាស់ និង ដឹកជញ្ជូនអាវុធ និងជាតិផ្ទុះ គ្រប់ប្រភេទសំរាប់កងកម្លាំងនគរបាលជាតិ និង ជនស៊ីវិល :

ក–ស្នងការដ្ឋាននគរបាលខេត្ត ក្រុង និង រាជធានីភ្នំពេញ មានសិទ្ធិចេញលិខិតអនុញ្ញាតដឹក ជញ្ជូនបានតែក្នុងភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវ ។

ខ–ការដឹកជញ្ជូនឆ្លងកាត់ខេត្ត ក្រុង ស្នងការនគរបាលខេត្ត ក្រុងត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ប្រការ ៣ : អំពីសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រើប្រាស់ និង ដឹកជញ្ជូនអាវុធ និងជាតិផ្ទុះគ្រប់ ប្រភេទសំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ :

ក–ក្រសួងការពារជាតិ ចេញលិខិតអនុញ្ញាតអោយដឹកជញ្ជូនអាវុធ ជាតិផ្ទុះគ្រប់ប្រភេទចេញពី ឃ្លាំងយុទ្ធសាស្ត្ររបស់ក្រសួង ផ្តល់ជូនឃ្លាំងអគ្គសេនាធិការ ។

ខ–អគ្គសេនាធិការ នៃកងយោធពលខេរភូមិន្ទ ចេញលិខិតអនុញ្ញាតអោយដឹក ជញ្ជូនអាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទដល់កងឯកភាព នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ពេលបើកចេញ ពីឃ្លាំង ។

គ–យោធភូមិភាគមានសិទ្ធិចេញលិខិតអនុញ្ញាតដឹកជញ្ជូនអាវុធ និងជាតិផ្ទុះគ្រប់ប្រភេទដល់កងពល និងតំបន់ប្រតិបត្តិការសឹករងដែលប្តូរទីតាំង និង ទៅប្រតិបត្តិការសឹកក្រៅភូមិសាស្ត្រ ។

ឃ–កងពល និង តំបន់ប្រតិបត្តិការសឹករង មានសិទ្ធិចេញលិខិតដឹកជញ្ជូនបានតែក្នុងភូមិ សាស្ត្រដែលខ្លួនទទួលខុសត្រូវ ។

ប្រការ ៤ : ចំពោះអាវុធពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ផ្នែកបច្ចេកទេសគ្រប់គ្រងអាវុធ និង ជាតិផ្ទុះ ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ត្រូវសហការស្រាវជ្រាវតាមសំណូមពរជាក់ស្តែង របស់ក្រសួង មហាផ្ទៃ ឬក្រសួងការពារជាតិ ។

ប្រការ ៥ : ហាមមិនអោយយកអាវុធវែង ខ្លី ជាតិផ្ទុះគ្រប់ប្រភេទចូលរាជធានីភ្នំពេញ ហើយត្រូវរក្សាទុកនៅប៉ុស្តិ៍ ត្រួតពិនិត្យអាវុធ និង ជាតិផ្ទុះតាមការកំណត់ដូចខាងក្រោមនេះ ÷

ក–តាមផ្លូវគោក :

១–ផ្លូវជាតិលេខ ១ (ចំណុចសង្កាត់និរោធ ខ័ណ្ឌមានជ័យ) ។

២–ផ្លូវជាតិលេខ ៣ (ចំណុចសង្កាត់ពងទឹក ខ័ណ្ឌដង្កោ) ។

៣–ផ្លូវជាតិលេខ ៤ (ចំណុចសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ) ។

៤–ផ្លូវជាតិលេខ ៥ (ចំណុចសង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ) ។

៥–ផ្លូវជាតិលេខ ៦ អា (ចំណុចសង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ) ។

ខ–តាមផ្លូវទឹក :

–កំពង់ផែដឹកជញ្ជូនអ្នកដំណើរភ្នំពេញ ។

គ–តាមផ្លូវដែក :

–ស្ថានីយ៍រាជាយស្វ័យយានភ្នំពេញ ។

ឃ–តាមផ្លូវអាកាស :

-អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។

ក្នុងករណីអាចអោយយកអាវុធ ចូលបានបើ ÷

-មានសំណូមពរយកអាវុធ ឬជាតិផ្ទុះមកធ្វើកោសល្យវិច្ច័យ ដោយមានលិខិតបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬ

-មានភារកិច្ចចាំបាច់ការពារអភិបាល អភិបាលរងខេត្ត ក្រុង មេបញ្ជាការ មេបញ្ជាការរង យោធភូមិភាគ មេបញ្ជាការ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង និង ស្នងការ ស្នងការរង ដែលមកបំពេញការងារនៅភ្នំពេញ អាចអោយយកអាវុធខ្លីមួយចំនួនសមស្របចូលបាន ឬ

-មានបេសកកម្មឆ្លងកាត់រាជធានីភ្នំពេញទៅបំពេញបេសកកម្មនៅខេត្ត ឬក្រុងមួយផ្សេង ទៀត ។

-កងឯកភាពនៅក្នុងរាជធានីភ្នំពេញ ត្រូវវិលពីប្រតិបត្តិការក្រៅរាជធានីភ្នំពេញ ។

-កងឯកភាពដែលមានភារកិច្ចប្រតិបត្តិការ យុទ្ធដំណើរត្រូវការឆ្លងកាត់ រាជធានីភ្នំពេញ ត្រូវយកលិខិតបញ្ជាបេសកកម្មបង្ហាញដល់ភ្នាក់ងារជំនាញមានសមត្ថកិច្ចដែលត្រួតពិនិត្យនៅច្រកចូលរាជធានីភ្នំពេញ ដើម្បីអោយភ្នាក់ងារនៅច្រកនោះជូនដំណើរ អោយផុតពីរាជធានីភ្នំពេញ ។

ផ្លូវដែលបានកំណត់ខាងលើ មិនអនុញ្ញាតអោយយកអាវុធ ឬ ជាតិផ្ទុះឆ្លងកាត់ជាដាច់ខាត។

ប្រការ ៦ : មន្ត្រីនគរបាលជាតិ ឬមន្ត្រីយោធាណាដែលបានចេញលិខិតអនុញ្ញាត អោយប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទផ្ទុយពីការកំណត់នៃ ប្រកាសអន្តរ ក្រសួងនេះ ត្រូវបណ្តេញចេញពីក្របខ័ណ្ឌ និង ផ្តន្ទាទោសតាមច្បាប់ ។

ប្រការ ៧ : ជនណាប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទផ្ទុយពីបទបញ្ញត្តិនៃប្រកាសនេះ ត្រូវដកហូតអាវុធជាតិផ្ទុះនោះ និងត្រូវបញ្ជូនខ្លួនទៅតុលាការផ្តន្ទាទោសតាមច្បាប់ ។

ប្រការ ៨ : លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ មានសុពលភាព ១ ឆ្នាំ ចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះនេះ ។

លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទចាស់មានសុពលភាពដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ ។

ប្រការ ៩ : នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ អគ្គសេនាធិការ និង គ្រប់ស្ថាប័នក្រោមឱវាទ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អភិបាលខេត្ត – ក្រុង មេបញ្ជាការយោធភូមិភាគ មេបញ្ជាការតំបន់ប្រតិបត្តិសឹករង ស្នងការនគរបាលខេត្ត–ក្រុង ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
ស ខេង យូ ហុកគ្រី	**ទៀ បាញ់ ទា ចំរ៉ាត់**

* * *

២ - អន្តរក្រសួង សាធារណការ និងដឹកជញ្ជូន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មហាផ្ទៃ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសរួមលេខ : ២៨១ ប្រក.សក

ស្តីពីការបន្តផ្តល់ផ្លាកលេខរថយន្ត ចត្តាឡីស្តាំ

អន្តរក្រសួង សាធារណការ និង ដឹកជញ្ជូន

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ - មហាផ្ទៃ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០–៩៤/៩០ ចុះថ្ងៃទី ៣១ ១០–១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសេចក្តីជូនដំណឹងលេខ ៣៨៧ សជណ.ពហ ចុះថ្ងៃទី ០១ ១០–១៩៩៣ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបញ្ឈប់ការនាំចូល រថយន្តចង្កូតស្តាំ ។
- បានឃើញលិខិតលេខ ១៦៩៥ សជណ.គម ចុះថ្ងៃទី ១៧–១០–១៩៩៤ របស់ទីស្តីការគណៈ រដ្ឋមន្ត្រី ស្តីអំពីករណីនាំចូលរថយន្តចង្កូតស្តាំ ។
- បានឃើញសេក្តីជូនដំណឹងលេខ ០១៤ សក ចុះថ្ងៃទី ១៣–៧–៩៥ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ស្តីពីការលែងផ្តល់ផ្លាកលេខ រថយន្តចង្កូតស្តាំ ។
- យោងតាមសំណូមពរ របស់ម្ចាស់យានយន្តចង្កូតស្តាំមួយចំនួនដែលមិន បានដាក់ពាក្យសុំផ្តល់ ផ្លាកលេខទាន់ពេលកំណត់ ។

សំរេច

ប្រការ ១ : រថយន្តចង្កូតស្តាំដែលម្ចាស់រថយន្តបានបង់ពន្ធរួច អនុញ្ញាតអោយមកធ្វើផ្លាក លេខសំគាល់រថយន្តនៅក្រសួងសាធារណការ និង ដឹកជញ្ជូន ក្នុងរយៈពេល ៦០ ថ្ងៃ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើប្រកាសរួមនេះ ។

ប្រការ ២ : ផុតរយៈពេលកំណត់ខាងលើ ក្រសួងសាធារណការ និង ដឹកជញ្ជូន មិន ទទួលខុសត្រូវក្នុងការផ្តល់ផ្លាកលេខជូនរថយន្តចង្កូតស្តាំទៀតឡើយ ហើយ ម្ចាស់រថយន្តត្រូវទទួលខុសត្រូវនៅចំពោះមុខក្រសួងមានសមត្ថកិច្ច ។

ប្រការ ៣ : លោកអគ្គនាយក នៃក្រសួងសាធារណការ និង ដឹកជញ្ជូន លោកអគ្គនាយក នគរបាលជាតិនៃក្រសួងមហាផ្ទៃ លោកនាយកទីចាត់ការគយ និង រដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោកនាយកមន្ទីរសាធារណការ និង

ដឹកជញ្ជូន ខេត្ត-ក្រុងមានភារកិច្ច អនុវត្តតាមសេចក្តីប្រកាសរួមចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា និង ត្រា
ស ខេង យូ ហុកគ្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
គាត ឈន់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ
និងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
អ៊ឹង ហួត

* * *

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤៥៩ ប្រក.ឧក រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន សាន់ ឌី កូអែលធីឌី (SANDY CO.LTD) តំណាង ដោយលោក **ជា សាន** ជនជាតិខ្មែរ អាយុ ៥១ ឆ្នាំ ភេទ ប្រុស អាស័យដ្ឋានផ្ទះលេខ ៧៣ Eo ផ្លូវ លេខ ១៣០ សង្កាត់ផ្សារថ្មីទី ៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៦៣៣២ ភព ចុះថ្ងៃទី ២៩-៣-៨៩ បង្កើត « រោងចក្រផ្លាស្ទិក » ដែលមានឈ្មោះ « រោងចក្រផ្លាស្ទិក សាន់ ឌី » មានទីតាំងស្ថិតនៅភូមិចុងថ្នល់ សង្កាត់ទឹកថ្លា ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផ្លាស្ទិក ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ « ផលិតផលពីផ្លាស្ទិក » ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬ ល្មើស ប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៦៣ ឧក.ប្រក រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ហ៊ុយ** ម្ចាស់សិប្បកម្មផលិតស្រាកែច្នៃ ដែលមានទីតាំងផ្ទះលេខ ៥៣២ ផ្លូវជាតិលេខ ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ ៦ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បើកសាខាផលិតកម្មស្រាកែច្នៃ ចំនួន១ កន្លែង ទៅទីតាំងផ្ទះលេខ ១៤ ផ្លូវលេខ ៣២៤ សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ទទួលស្គាល់លោក **សុខ ហួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១១១៥៨ ភ.ព ចុះថ្ងៃទី ២២ -៤-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៤ ផ្លូវលេខ ៣២៤ សង្កាត់ បឹងសាឡាង ខណ្ឌចំការមន រាជធានីភ្នំពេញ ជាប្រធានសាខាផលិតកម្មស្រាកែច្នៃ ដែលមានទីតាំង ដូចមានចែងក្នុងប្រការ១ ។

ប្រការ ៣ : លោក **សុខ ហួត** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលស្រាកែច្នៃ ចំនួន បី មុខ គឺស្រាសញ្ញា « ផ្លែទៀបបារាំង » ស្រាសញ្ញា «ត្រចៀកកាំ » និងស្រាសញ្ញា « ផ្លែតៀមឬយជូអែម » ស្របតាមគំរូសញ្ញាសំគាល់ ដែល

បានតំកល់នៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រការ៣ដែលមានចែងក្នុងប្រកាសលេខ ៧៨៩ ផក.ប្រក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៥ នៅមានតម្លៃជាធរមានបញ្ញត្តិដដែល ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ិត ប្រាំង

* * *

៤- ទីស្តីការក្រសួងមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២២៦/៩៦ ពម.មពប្រក

អនុញ្ញាតឱ្យសារព័ត៌មានឈ្មោះ «សាធារណរដ្ឋ »

ដំណើរការបោះផ្សាយឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ តាមព្រះរាជក្រម លេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ១៩៩៥
- បានឃើញប្រកាសអនុញ្ញាតរបស់ក្រសួងព័ត៌មានលេខ ២៦០/៩៥ពមប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ ។

- បានឃើញប្រកាសផ្ទាករបស់ក្រសួងពត៌មានលេខ ០៤៩/៩៦ ពមប្រក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។
- បានឃើញលិខិតលោក លឹម រតនា ចុះថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មានឈ្មោះ សាធារណរដ្ឋ ដំណើរការឡើងវិញដោយមានលោក **លឹម រតនា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៤ អាអី ០ ផ្លូវ ១១២ សង្កាត់ផ្សារដេប៉ូ ២ ខ័ណ្ឌ ទួលគោក ។ ក្នុងករណីមានការផ្លាស់ប្តូរ នៅចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកសារពត៌មាន និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ ប្រពៃណី និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងផ្តល់សារពត៌មាន ៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាមីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោកចាងហ្វាងសារពត៌មាន សាធារណរដ្ឋ ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២២៧/៩៦ ពម.បសឧ.ប្រក

អនុញ្ញាតជូនអ្នកស្រី លី ហួរ បើកអាជីវកម្មបោះពុម្ពផ្ទាកសញ្ញា

ផលិតលើក្រដាស « ភ្នំពេជ្រ »

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤ /៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ ។
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មបោះពុម្ពផ្ទាកសញ្ញាផលិត «ភ្នំពេជ្រ »របស់អ្នកស្រី លី ហួរ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជូនអ្នកស្រី **លី ហួរ** អាស័យដ្ឋានផ្ទះលេខ ២៤៦ អឺ ២ ផ្លូវលេខ ៩៣ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មបោះពុម្ពផ្ទាកសញ្ញាផលិតលើក្រដាស «ភ្នំពេជ្រ » ស្ថិតនៅផ្ទះលេខ ២៦ ផ្លូវលេខ ៧៥ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅ នឹងទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្ត តាមភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១ - ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣៨២ ប្រក.កសក.ចត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ. ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ។

- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីការដាក់ អគ្គនាយកដ្ឋានចំការកៅស៊ូអោយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមស្មារតីអង្គប្រជុំអចិន្ត្រៃយ៍ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ កាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងតម្លើងឋានៈលោក **យិន សុខ** បច្ចុប្បន្នមន្ត្រីរាជការ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ អគ្គនាយកដ្ឋានចំការកៅស៊ូ ជាអនុប្រធាននាយកដ្ឋាន ផែនការ- ស្ថិតិ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : អគ្គនាយក ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ -ហិរញ្ញវត្ថុ អគ្គនាយកចំការកៅស៊ូ និងសាម៉ីជន ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សែងហួរ

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៣៨៥ សសរ.កសក.ចត

ស្តីពីការតែងតាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សា

សំរាប់ឆ្នាំសិក្សា ១៩៩៦

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធ ចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៨៤ ស្តីពីការបើកសាលាបច្ចេកទេសកសិកម្ម នៅសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប ។
- តាមសំណើលេខ ១០៧ សពល.កស ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៦ របស់សាលាមធ្យមសិក្សា កសិកម្មព្រែកលៀប

សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការប្រឡងបញ្ចប់ការសិក្សាមួយដូចរាយនាមខាងក្រោម :

១-ឯកឧត្តម **ម៉ៃ សំអឿន**	តំណាងក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ	ប្រធាន
២-លោក **នួន ស៊ិន**	ប្រធាននាយកដ្ឋាន បុគ្គលិក	អនុប្រធាន
៣-លោក **ខាយ ស៊ុនហ៊ាង**	នាយកសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប	អនុប្រធាន
៤-លោក **នួច សឿម**	នាយករងសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប	លេខាធិការ
៥-លោក **ឡិ សឿន**	អនុប្រធាននាយកដ្ឋានរុក្ខាប្រមាញ់	សមាជិក
៦-លោក **ហាស់ សុខ**	អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ	សមាជិក

៧–លោក **សោម សួន** អនុប្រធាននាយកដ្ឋានផលិតកម្មនិង បសុព្យាបាល សមាជិក

៨–លោក **លី ចាន់ណា** អនុប្រធាននាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ សមាជិក

៩–លោក **លឹម ហោ** អនុប្រធាននាយកដ្ឋានសុរិយោដី សមាជិក

១០–លោក **នាង សុខឃីម** អនុប្រធានការិយាល័យរៀបចំកម្មវិធីសិក្សា សមាជិក

១១–លោក **ចាន់ ឧត្តធី** អនុប្រធានការិយាល័យរដ្ឋបាល ចាត់តាំង សមាជិក

១២–លោក **ខៀវ កន** អនុប្រធានស្ថានីយ៍អនុវត្តជាក់ស្តែង សមាជិក

ប្រការ ២ : ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ មានភារកិច្ចរៀបចំការប្រឡងបញ្ចប់ការសិក្សាសិស្សថ្នាក់បឋម ២ ថ្នាក់ ថ្នាក់មធ្យម ៤ ថ្នាក់ ក្នុង ខែ កក្កដា ឆ្នាំ ១៩៨៦ អោយប្រព្រឹត្តទៅបានលទ្ធផលល្អ ។

ប្រការ ៣ : អគ្គនាយក ក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយ-កដ្ឋានគណនេយ្យហិរញ្ញវត្ថុ–ប្រធាននាយកដ្ឋានផែនការ ស្ថិតិ-បណ្តុះអង្គភាពពាក់ព័ន្ធ–នាយកសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប និង សាមីជនត្រូវទទួលបន្ទុកអនុវត្តនូវសេចក្តីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ឈា សុខ

* * *

៦ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១២២ ប្រក.វវស.ប្រ

ស្ដីពីការបង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ និង កំណែលស្នាដៃបច្ចេកទេសសំរាប់ការប្រឡងបញ្ចប់បរិញ្ញា ឆ្នាំសិក្សា ១៩៩៥ - ៩៦របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ និង កំណែស្នាដៃបច្ចេកទេសរបស់មហាវិទ្យាល័យបុរាណវិទ្យា ដែលមានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម **នុត ណារ៉ាង**	ប្រធាន
២–លោក **នុយ គឿន**	អនុប្រធាន
៣–លោក **ដុច គឿន**	អនុប្រធាន
៤–លោក **អាំង ជូលាន**	សមាជិក
៥–ឯកឧត្តម **ស៊ន សូប៊ែរ**	សមាជិក

ប្រការ ២ : បង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ និង កំណែស្នាដៃបច្ចេកទេសរបស់មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ដែលមានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម **នុត ណារ៉ាង**	ប្រធាន
២–លោក **នុយ គឿន**	អនុប្រធាន
៣–លោក **គឿង សុគណ្ធី**	អនុប្រធាន
៤–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ គុណសំគ**	សមាជិក
៥–លោក **នីវ ទិណ្ឌ**	សមាជិក
៦–សាស្ត្រាចារ្យចំនួន ៣ រូបមកពីក្រសួងក្រៅ	សមាជិក

ប្រការ ៣ : បង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ និង កំណែស្នាដៃបច្ចេកទេសរបស់មហាវិទ្យាល័យសិល្បៈសូនរូបដែលមានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម **នុត ណារ៉ាង**	ប្រធាន
២–លោក **នុយ គឿន**	អនុប្រធាន
៣–លោក **ម៉ៅ ឡឿង**	អនុប្រធាន
៤–លោក **ចាប ស្វន**	សមាជិក
៥–លោក **អ៊ុំ មេត្តាសិញ**	សមាជិក
៦–លោក **ថោង សុផន**	សមាជិក
៧–លោក **អេង សុវត្ថិឌី**	សមាជិក

ប្រការ ៤ : បង្កើតគណៈកម្មការលេខាធិការដ្ឋានមួយសំរាប់សម្រួលការងារ ដែលមានសមាសភាពដូចខាងក្រោម :

១–លោក **ចាប ស្វន**	ប្រធាន
២–លោក **ចាប សុវណ្ណ**	អនុប្រធាន
៣–លោក **ស្វន ស៊ី**	សមាជិក

៤–លោក **គុំ សុរិទ្ធ**	សមាជិក
៥–លោក **ផ្លូង រតនៈ**	សមាជិក
៦–លោក **ស៊ឹង គឹមយ៉ុន**	សមាជិក
៧–អ្នកស្រី **តាន់ ឆុំ**	សមាជិក
៨–លោក **មាស វណ្ណា**	សមាជិក
៩–លោក **រស់ សំអឿន**	សមាជិក
១០–អ្នកស្រី **យឹម រដ្ឋា**	សមាជិក
១១–លោក **សំ ហួត**	សមាជិក
១២–លោក **ជ័យ ឫទ្ធី**	សមាជិក
១៣–លោក **ថាច មុយថូ**	សមាជិក
១៤–កញ្ញា **ឯម សុគន្ធា**	សមាជិក
១៥–កញ្ញា **ដួង សារ៉ិន**	សមាជិក

ប្រការ ៥ : បង្កើតគណៈកម្មការកំណែស្នាដៃបច្ចេកទេសសំរាប់មហាវិទ្យាល័យសិល្បៈ សូនរូបដែលមានសមាសភាព ដូចខាងក្រោម :

១–លោក **ខួត ប៊ុនឈាង**

២–លោក **ស៊ិន ចាន់ថន**

៣–លោក **ប៉ែន ឈាងស្រុង**

៤–លោក **ស្រៀង អ៊ី**

៥–លោក **ហេង មុនីផល**

៦–អ្នកស្រី **ស្ងួស សុជារី**

៧–លោក **គី ចាន់ថន**

៨–លោក **ឈឿន រិទ្ធី**

៩–លោក **ប៊ុច សុខ**

១០–លោក **ហោ គឹមស្រ៊ាន**

ប្រការ ៦ : ខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

៧ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៦៥១ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់គ្រូ

« គណិតវិទ្យាថ្នាក់ទី ៧ »

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា ធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល

ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធ អប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យមើលសៀវភៅ គណិតវិទ្យាថ្នាក់ទី៧ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសំរាប់គ្រូ « គណិតវិទ្យាថ្នាក់ទី៧ » ដែលជាស្នាដៃ និពន្ធរបស់គណៈកម្មការគណិតវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និង កីឡា រៀបរៀងដោយលោក [illegible] **គីម ស្រ៊ុន** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ ២ : មន្ទី នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៨ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ ១២៦៥ ប្រក.អជប

ស្តីពីការចាត់តាំងមន្ត្រីរាជការអោយធ្វើជាដៃគូជាមួយ

ជំនាញការក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទ កម្ពុជា ឥណ្ឌូនេស៊ី

(Indonesia- Cambodia Rural Development Project)

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមា សភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលឥណ្ឌូនេស៊ី និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

ប្រការ ១ : ចាត់តាំងមន្ត្រីរាជការដែលមានឈ្មោះខាងក្រោមអោយធ្វើជាដៃគូរ (Counterparts) ជាមួយអ្នកជំនាញការឥណ្ឌូនេស៊ីក្នុងកម្មវិធី អភិវឌ្ឍន៍ជនបទកម្ពុជា ឥណ្ឌូនេស៊ី (ICRDP) :

- លោក **ហៀង ជុនធៀង** មន្ត្រីនាយកដ្ឋានសេដ្ឋកិច្ចជនបទ
- លោក **មិន សាម៉ុន** មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង

ប្រការ ២ : មន្ត្រីរាជការដែលបានចាត់តាំងក្នុងប្រការ ១ មានភារកិច្ចសហការជាមួយអ្នកជំនាញការរបស់កម្មវិធី ICRDP ដើម្បី អោយកម្មវិធីនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានទាំង ២ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង និងសាម៉ីជន ត្រូវអនុវត្តតាម ប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ទេង់ ហុង ស៊ុនហួត

* * *

៩ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងបរិស្ថាន

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ ១១៦៤ បស្ត

ស្តីពីការតែងតាំង និងតំលើងឋានៈមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយ ព្រះរាជក្រម

ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រមលេខ នស. ករម.០១៩៦២១ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- ពិនិត្យលើការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងលោក **អេង តាយម៉េង** ជាប្រធានការិយាល័យទទួលបន្ទុកមន្ទីរពិសោធន៍ បរិស្ថាន នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវកែសំរួលតាមតួនាទី និងភារកិច្ច។

ប្រការ ៣ : មន្ទីរ. អគ្គនាយក អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ ១១៦៥ ប.ស្ត

ស្តីពីការតែងតាំង និងតំលើងឋានៈមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស.ករម.០១៩៦២១ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- ពិនិត្យលើការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងលោក **ឡុញ ម៉ារ៉ាឈ** ជាអនុប្រធាននាយកដ្ឋាន ត្រួតពិនិត្យការបំពុលបរិស្ថាន ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗត្រូវកែសំរួលតាមតួនាទី និងភារកិច្ចថ្មី។

ប្រការ ៣ : មន្ទីរ អគ្គនាយក អង្គភាពពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ ១១៦៦ ប.ស្ថ

ស្តីពីការតែងតាំង និងតំឡើងឋានៈមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស.ករម.០១៩៦២១ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- ពិនិត្យលើការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ផ្ទេរនិងតែងតាំងលោក **ជី សុខណា** បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានអប់រំ និងពត៌មាន បរិស្ថាន ជាប្រធាននាយកដ្ឋានស្តីទី នៃនាយកដ្ឋានគ្រប់គ្រងធនធានសេដ្ឋកិច្ចសង្គម និងទិន្នន័យ និង នៃក្រសួងបរិស្ថាន ។

ប្រការ ២ : មន្ទីរ អគ្គនាយក អង្គភាពពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

១០ - រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ ៤៣៨ សសរ.មស.ក្រខ

ស្តីពីការបែងចែកសិស្ស និស្សិត ចំនួន ១០ នាក់

ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨-២-៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ កំរិត ១ ចំនួន ០២ នាក់ និងអ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០៨ នាក់ ដែលបានបញ្ចប់ការសិក្សាពីក្រៅប្រទេស ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមក្រសួង ស្ថាប័ន មួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេច មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ច្រាក់ សុខ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦

តារាងឧបសម្ព័ន្ធ នៃសេចក្ដីសំរេចលេខ ៤៣៨
មស.ក្រខ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៦
ស្ដីពីការបែងចែកសិស្សនិស្សិតចំនួន ១០នាក់ដែល
ទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំ កំណើត	អង្គភាពដើម	មុខជំនាញ បច្ចេកទេស	បៀវត្ស	ប្រភពបណ្ដុះ បណ្ដាល
	១ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ០៤ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ៤ នាក់						
១	មាម ស៊ីតូ	ប	១៣-១០-៦៩	សិស្ស	រុក្ខកម្ម	៩០ ខ.I.១	៣
២	អៀ វណ្ណា	–	១៥-០៧-៧១	–	–	-	-
៣	ឯម វិចិត្រ	–	០៣-១២-៦៩	–	–	-	-
៤	ប៊ុន ឈុន	–	២៤-០៩-៦៩	–	សេដ្ឋកិច្ច ព្រៃឈើ	-	-
	២ - ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០២ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ០២ នាក់						
៥	ស៊ីង សេណូ	ប	១១-១១-៦៦	សិស្ស	បើកបរនាវា	៩០ ខ .I.១	១
៦	ឡុង សារុន	–	១៥-០៨-៦៦	–	សំណង់ស៊ីវិល និង ឧស្សាហកម្ម	-	-
	៣ - ទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់ឧត្ដម ចំនួន ០១ នាក់						
៧	ឡាយ សៀងលី	ប	០៣-៣-៦៣	មន្ត្រីទីស្ដីការ គណៈរដ្ឋមន្ត្រី	ផែនទីវិទ្យា	ខ .I.១	១
	៤ - ក្រសួងសុខាភិបាល ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវេជ្ជសាស្ត្រកិត ១ ចំនួន ០១ នាក់						
៨	តៅ វាសនា	ប	៣១-១២-៥៣	មន្ត្រីក្រសួង សុខាភិបាល	សល្យសាស្ត្រកុមារ	ខ .I. ៤	២
	៥ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០១ នាក់						
	ក - អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រកិត ១ ចំនួន ០១ នាក់						
៩	គួច ច័ន្ទត្រីស្នា	ប	៣១-៨-៥៩	មន្ត្រីសាលា មធ្យមសិក្សា ឫស្សីកែវ	សេដ្ឋកិច្ច	ខ .I. ៤	១

៦ - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០១ នាក់

ក - អ្នកបច្ចេកទេសថ្នាក់ឧត្តម ចំនួន ០១ នាក់

១០	ប៊ុន ឃុននី	ប	១២-៧-៧៣	សិស្ស	ច្បាប់អន្តរជាតិ	៩០ ខ.I.១	៣

បានបញ្ឈប់បញ្ជីត្រឹមចំនួន ១០ នាក់ « ដប់ » ប៉ុណ្ណោះ

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

កំណត់សំគាល់

១ - ប្រទេស រុស្ស៊ី

២ - ប្រទេស អាល្លឺម៉ង់

៣ - ប្រទេស វៀតណាម

* * *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៧៥០ រៀល